**ស្ថានទូតជប៉ុន**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០១ ខែមិនា ឆ្នាំ២០១៦

**ជប៉ុនផ្តល់ជូនថវិកាចំនួន ៧៦៦,០៣៩ដុល្លារអាមេរិក សម្រាប់សន្តិសុខស្បៀង និងអាហាររូបត្ថម្ភ និងបង្កើនសមត្ថភាពបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាម**

ក្រោមគ្រោងការណ៍នៃជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាចំនួន២៥,០៤៨,៨៧០យ៉េន (ប្រមាណជា ២២៧,៧១៧ដុល្លារអាមេរិក) ដល់អង្គការមូលនិធិសម្រាប់ការអភិវឌ្ឍ និងជំនួយសង្គ្រោះអន្តរជាតិ និងផ្តល់ជូនថវិកាចំនួន៥៩,២១៥,៤២០ (ប្រមាណជា ៥៣៨,៣២២ដុល្លារអាមេរិក) ដល់អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)។ កិច្ចសន្យាផ្តល់ជំនួយថ្ងៃនេះ ត្រូវបានចុះហត្ថលេខាដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រី តាកាហាស៊ី អាគីមិ នាយិកាអង្គការFIDR ដើម្បីអនុវត្តគម្រោងសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ ដំណាក់កាលទី៣ ប្រចាំខេត្តកំពង់ឆ្នាំង និងលោក សាកូ ណាហ្គាតូស៊ី ប្រធានតំណាងអង្គការ JMAS ដើម្បីអនុវត្ត "គម្រោងបង្កើនសមត្ថភាពបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាមដល់អង្គការ CMAC ដំណាក់កាលទី២"។

១. <u>គម្រោងសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ ដំណាក់កាលទី៣ ប្រចាំខេត្តកំពង់ឆ្នាំង</u>

គម្រោងនេះ គឺដើម្បីបង្កើនផលិតភាពនៃការធ្វើស្រែ ពិពិធកម្មនៃការដាំបន្លែនិងចិញ្ចឹមសត្វ កែលម្អចំណេះដឹងផ្នែកអាហាររូបត្ថម្ភសម្រាប់កុមារ និងបង្កើតបណ្តាញទំនាក់ទំនងរវាងកសិករនិងកសិករនៅក្នុងភូមិគោលដៅចំនួន៣៩ ក្នុងស្រុករលាប្អៀរ និងស្រុកបរិបូរណ៍ ក្នុងខេត្តកំពង់ឆ្នាំង។ លើសពីនេះ គម្រោងនេះ ត្រូវបានរំពឹងថា នឹងរួមចំណែកក្នុងការគាំទ្រការបង្កើត និងការគ្រប់គ្រងមជ្ឈមណ្ឌលកសិកម្ម។

២. <u>គម្រោងបង្កើនសមត្ថភាពបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាមដល់អង្គការCMACដំណាក់កាលទី២</u>

គម្រោងនេះ គឺដើម្បីបង្កើនសមត្ថភាពចំណេះដឹងជំនាញដល់គ្រូបង្រៀន និងសមាជិកក្រុមCMAC ជាពិសេសការគ្រប់គ្រងនៅលើទីវាល និងបច្ចេកទេសសុវត្ថិភាពនានា ក្រោមជំនួយផ្នែកបច្ចេកទេសពីអ្នកប្រឹក្សារបស់អង្គការJMAS នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនរបស់CMAC នៅខេត្តកំពង់ឆ្នាំង។ តាមរយៈគម្រោងនេះ យើងរំពឹងថា គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណជា ២៤០,000នាក់ ដោយធ្វើការកាត់បន្ថយនូវការគំរាមកំហែងពីកាកសំណល់ជាតិផ្ទុះពីសង្គ្រាម និងឈានទៅរកការអភិវឌ្ឍសហគមន៍នៅពេលដែលតំបន់នោះត្រូវបានបោសសម្អាតរួច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង២៥លានដុល្លារអាមេរិក ដល់គម្រោងចំនួន៩១ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីន។ គម្រោងទាំងពីរដែលត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ គឺជាគម្រោងទី៣ និងជាគម្រោងទី២ ដែលទទួលបានថវិកាតាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៥របស់ជប៉ុន (មេសា២០១៥ដល់មិនា២០១៦)។

---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*